<u>អន្ទាក់កណ្ដុរ</u>

*(បកប្រែពីភាសាបរទេស)*

ថ្ងៃមួយ មានកណ្ដុរមួយបានលួចមើលកសិករពីនាក់ប្ដីប្រពន្ធតាមប្រហោងជញ្ជាំង ដែលកំពុងតែរើអីវ៉ាន់ដែលពួកគាត់ទើបតែបានទិញពីផ្សារ ដែលលោមានចំណីដែលខ្លួនអាចស៊ីបាន។ កណ្ដុរមានការតុកស្លុតយ៉ាងខ្លាំង នៅពេលដែលវាបានឃើញអន្ទាក់សម្រាប់ដាក់វា។

កណ្ដុរបានរត់ចេញទៅខាងក្រៅផ្ទះ ហើយបានស្រែកប្រកាសអាសន្នថា "មានអន្ទាក់កណ្ដុរនៅក្នុងផ្ទះ!!! ម្ដងហើយម្ដងទៀត"។

មេមាន់ដែលឮសម្រែករបស់កណ្ដុរមុនគេ បានងក់ក្បាលតិចៗ ហើយនិយាយទៅកាន់កណ្ដុរថា "សំឡាញ់ ខ្ញុំយល់ថាសំឡាញ់ពិតជាមានការតក់ស្លុតយ៉ាងខ្លាំង នៅពេលបានឃើញអន្ទាក់សម្រាប់ដាក់ខ្លួនឯងយ៉ាងដូច្នេះ។ អន្ទាក់នោះមិនមែនសម្រាប់ដាក់គ្នានោះទេ ដូច្នេះគ្នាហាក់ដូចជាគ្មានអ្វីត្រូវបារម្ភនោះទេ"។

កណ្ដុរក៏បន្តដំណើររបស់ខ្លួនទៅមុខទៀត ហើយបានជួបជ្រូក។ វាបានប្រាប់ជ្រូកថា"មានអន្ទាក់សម្រាប់ដាក់កណ្ដុរនៅក្នុងផ្ទះ"។

ជ្រូកអាណិតអាសូរកណ្ដុរយ៉ាងខ្លាំង ហើយបាននិយាយទាំងស្រងូតស្រងាត់ថា "សំឡាញ់ គ្នាមិនអាចជួយអ្វីដល់ឯងបានទេ ក្រៅតែពីការបួងសួង សូមឲ្យសំឡាញ់បានសេចក្ដីសុខ រួចពីអន្ទាក់នោះទេ"។

កណ្ដុរក៏បានយករឿងដែលកសិករទិញអន្ទាក់ដាក់កណ្ដុរទៅប្រាប់គោ។ គោបានឆ្លើយយ៉ាងប្រងើយដាក់កណ្ដុរវិញថា "អន្ទាក់សម្រាប់ដាក់ឯងប៉ុណ្ណោះ មិនមែនសម្រាប់ដាក់គ្នានោះទេ"។

កណ្ដុរក៏បានត្រលប់មកផ្ទះកសិករវិញ រកមើលថាតើអន្ទាក់នោះនៅកន្លែងណា ទាំងការភិតភ័យ និងអស់សង្ឃឹមតែម្នាក់ឯង។

នៅយប់នោះ មាសំឡេងឮពេញផ្ទះ ដូចជាសំឡេងអន្ទាក់ ដែលវាត់ជាប់សត្វអ្វីមួយយ៉ាងដូច្នេះ។ ប្រពន្ធកសិករនោះបានប្រញ៉ាប់ប្រញ៉ាល់ទៅពិនិត្យ ក្រែងលោអន្ទាក់របស់ខ្លួនចាប់បានកណ្ដុរហើយ។ នៅក្នុងទីងងឹតគាត់មិនបានឃើញពស់ពិសដែលមានកន្ទុយជាប់អន្ទាក់នោះទេ។ ពស់ក៏បានចឹកគាត់។ ប្ដីរបស់គាត់បានយកគាត់ទៅមន្ទីរពេទ្យ ហើយគាត់មានអាការៈក្ដៅខ្លួន។

នៅក្នុងភូមិនោះ អ្នកភូមិគ្រប់គ្នាយល់ថា ស៊ុបមាន់ក្ដៅៗអាចជួយឲ្យអ្នកមានអាការៈក្ដៅខ្លួនធូរស្រាលបាន។ កសិករនោះក៏បានសម្លាប់មាន់ដើម្បីធ្វើស៊ុបឲ្យប្រពន្ធគាត់ហូប។

ជំងឺមិនបានធូរស្រាលនោះទេ។ មិត្តភក្តិ និងអ្នកជិតខាងរបស់គាត់បានមកសួរសុខទុក្ខជាហូរហែរ។ ដោយសារគាត់គ្មានអ្វីទទួលភ្ញៀវ គាត់ក៏បានសម្លាប់ជ្រូ ដើម្បីធ្វើម្ហូបទទួលទានទៅ។

ប៉ុន្មានសប្តាហ៍ក្រោយមកទៀត ប្រព័ន្ធរបស់គាត់ក៏ស្លាប់ទៅ។ នៅក្នុងពិធីបុណ្យសព កសិករបានឱ្យគេសម្លាប់គោធ្វើម្ហូបទទួលភ្ញៀវទៀតទៅ។

**ជីវិតគឺជាការរួមសុខរួមទុក្ខជាមួយគ្នា។**

កាលណានរណាម្នាក់បម្រុងនឹងមានគ្រោះថ្នាក់ អ្នកឯទៀតក៏មិនប្រកដថាជាបានសេចក្តីសុខនោះដែរ។

*(លោក Martin Luther King Jr (សកម្មជនសិទ្ធិមនុស្ស អាមេរិកស្បែកខ្មៅ))*

"អំពើអយុត្តិធម៌នៅកន្លែងណាមួយ/ចំពោះមនុស្សណាម្នាក់ គឺជាការគម្រាមកំហែងយ៉ាងពិតប្រាកដទៅដល់អំពើយុត្តិធម៌នៅគ្រប់ទីកន្លែង/ចំពោះមនុស្សគ្រប់រូប"